**កម្មវត្ថុ៖ ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន – កិច្ចប្រជុំដោយផ្ទាល់និងតាមអនឡាញ –  ថ្ងៃទី 21 ខែសីហា ឆ្នាំ 2025**

ភាគីពាក់ព័ន្ធយុត្តិធម៌បរិស្ថានទាំងអស់ជាទីគោរព!

ការិយាល័យប្រតិបត្តិកិច្ចការថាមពល និងបរិស្ថាន (EEA) សូមអញ្ជើញក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន (EJC) ដើម្បីចូលរួមក្នុងកិច្ចប្រជុំបន្ទាប់របស់ខ្លួននៅ**ថ្ងៃទី 21 ខែសីហា ឆ្នាំ 2025 វេលាម៉ោង 6:30 ល្ងាច (ម៉ោងស្តង់ដាខាងកើត)**។
សមាជិកក្រុមប្រឹក្សានឹងពិភាក្សាអំពីច្បាប់កែលម្អហេដ្ឋារចនាសម្ព័ន្ធបរិស្ថានរដ្ឋម៉ាសាឈូសិត (ពង្រាងច្បាប់វិនិយោគបរិស្ថាន)
ពេលវេលា មួយចំនួននឹងត្រូវបានបែងចែកក្នុងអំឡុងពេលកិច្ចប្រជុំសម្រាប់មតិយោបល់ទូទៅពីសាធារណជន។

**សូមចុះឈ្មោះចូលរួមកិច្ចប្រជុំដោយប្រើតំណភ្ជាប់នេះ៖**
https://www.zoomgov.com/webinar/register/WN_M-WdKhURQ-aEgMWpWjijSw

**ការរៀបចំកិច្ចប្រជុំ៖** កិច្ចប្រជុំកូនកាត់នេះនឹងត្រូវបានរៀបចំឡើងតាមអនឡាញតាមកម្មវិធី Zoom និងដោយផ្ទាល់នៅវិទ្យាល័យ Drury High School ក្នុងទីក្រុង North Adams។ កិច្ចប្រជុំនេះត្រូវបានប៉ាន់ស្មានថាមានរយៈពេល 90 នាទី។ អាសយដ្ឋានគឺ  1130 Church St, North Adams, MA 01247 ហើយអាចប្រើមធ្យោបាយធ្វើដំណើរមកដល់ទីតាំងនេះដោយឡានក្រុងខ្សែលេខ 1 និង 34។ ចំណតឡានក្រុងដែលនៅជិតបំផុតគឺនៅ North Adams Walmart។ ចំណតរថយន្តមាននៅចំណតវិទ្យាល័យ Drury High School។

**ជំនួយផ្នែកបកប្រែ៖** ការបកប្រែតាមអនឡាញនឹងមានជាភាសាអេស្ប៉ាញ ព័រទុយហ្គាល់ ចិនកុកងឺ វៀតណាម ហៃទី ក្រេអូល និងភាសាសញ្ញាអាមេរិក (ASL)។ ប្រសិនបើអ្នកត្រូវការការបកប្រែជាភាសាជាក់លាក់ ឬការរៀបចំបន្ថែម សូមបញ្ជូល សំណើនោះក្នុងអ៊ីមែលផ្ញើទៅកាន់ meetings@erg.com។ សំណើផ្សេងៗត្រូវតែដាក់ជូនក្នុង រយៈពេល 48 ម៉ោងមុនពេលចាប់ផ្តើមកិច្ចប្រជុំ។
ដើម្បីទទួលបានព័ត៌មាននេះជាភាសាអង់គ្លេសអក្សរពុម្ពធំ ឬអក្សរស្ទាបសម្រាប់មនុស្សពិការភ្នែក សូមហៅទូរសព្ទទៅលេខ 1-877-623-6765។ TTY៖ 1877-623-7773។

**ច្បាប់ប្រជុំដោយបើកចំហ៖** ក្រុមប្រឹក្សា EJ ប្រតិបត្តិការក្រោមច្បាប់ប្រជុំដោយបើកចំហ [https://www.mass.gov/the-open-meeting-law] ហើយស្វាគមន៍សមាជិកសាធារណជនទាំងអស់ដែលមានបំណងចង់ចូលរួមសង្កេតកិច្ចប្រជុំបើកចំហរបស់ខ្លួន។ ក្នុងអំឡុងពេលប្រជុំនេះ អ្នកសង្កេតការណ៍អាចបញ្ចេញមតិ ឬសួរទៅក្រុមប្រឹក្សា EJ ដោយ មានការអនុញ្ញាតពីប្រធានអង្គប្រជុំ។

**ព័ត៌មានបន្ថែមអំពីក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន (EJC)៖** EJC ត្រូវបានតែងតាំងដោយអភិបាលដើម្បីផ្តល់យោបល់ និងផ្តល់អនុសាសន៍ដល់រដ្ឋមន្ត្រី EEA អំពីគោលនយោបាយ និងស្តង់ដាដែលពាក់ព័ន្ធ ដើម្បីសម្រេចបាននូវគោលការណ៍យុត្តិធម៌បរិស្ថាននានា។ គោលការណ៍ទាំងនេះត្រូវបានកំណត់ដោយច្បាប់របស់រដ្ឋថាជា “គោលការណ៍ដែលគាំទ្រ ការការពារពីការបំពុលបរិស្ថាន និងសមត្ថភាពក្នុងការរស់នៅក្នុងបរិស្ថានស្អាត និងមាន សុខភាពល្អ ដោយមិនគិតពីពូជសាសន៍ ពណ៌សម្បុរ ប្រាក់ចំណូល វណ្ណៈ ពិការភាព អត្តសញ្ញាណយេនឌ័រ ទំនោរផ្លូវភេទ ដើមកំណើតជាតិ ជាតិសាសន៍ ឬពូជពង្ស ជំនឿសាសនា ឬជំនាញភាសាអង់គ្លេស ដែលរួមមាន៖ (i) ការចូលរួមយ៉ាងសកម្មរបស់ប្រជាជនទាំងអស់ ពាក់ព័ន្ធនឹងការអភិវឌ្ឍ ការអនុវត្ត និងការពង្រឹងការអនុវត្តច្បាប់ បទបញ្ញត្តិ និង គោលនយោបាយបរិស្ថាន ដោយរួមទាំងគោលនយោបាយស្តីពីបម្រែបម្រួលអាកាសធាតុ និង (ii) បំណែងចែកប្រកបដោយសមធម៌នូវថាមពល

និងផលប្រយោជន៍បរិស្ថាន ព្រមទាំងបន្ទុក បរិស្ថាន។” ច្បាប់នេះត្រូវបានចែងត្រង់ផ្នែក 62L ក្នុងតំណនេះ៖ [https://malegislature.gov/Laws/SessionLaws/Acts/2021/Chapter8].

ព័ត៌មានបន្ថែមអំពី EJC របៀបវារៈនៃកិច្ចប្រជុំនាពេលខាងមុខ និងរបាយការណ៍កិច្ចប្រជុំកន្លងមក អាចរកបាននៅទីនេះ៖ https://www.mass.gov/orgs/environmental-justice-council. សូមចុចលើពាក្យ “Select Language” នៅខាងលើផ្នែកខាងស្តាំនៃគេហទំព័រ ដើម្បីបកប្រែទំព័រនេះ។

សូមអរគុណ!

María Belén Power
អនុរដ្ឋមន្ត្រីសមធម៌និងយុត្តិធម៌បរិស្ថាន
ការិយាល័យប្រតិបត្តិកិច្ចការថាមពលនិងបរិស្ថាន